# ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់

ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (យូភីអ) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិ អនុវត្តតាមរយៈការត្រួតពិនិត្យទៅលើការគោរពប្រតិបត្តិទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋនីមួយៗ ដែលជាសមាជិកអង្គការសហប្រជាជាតិ ។

ក្នុងអំឡុងពេលយូភីអ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិផ្តល់អនុសាសន៍ដល់រដ្ឋដែលត្រូវទទួលការត្រួតពិនិត្យអំពីវិធីនានាដែលអាចធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរ។

ដំណើរការនេះធ្វើឡើងចំពោះប្រទេសនីមួយៗរៀងរាល់ពេល៥ឆ្នាំម្តង ជាទៀងទាត់។

៥ឆ្នាំ

## យូភីអ សម្រាប់ប្រទេសកម្ពុជា



ជុំទី១ នៅខែធ្នូ ឆ្នាំ២០០៩ ›››› ជុំទី២ នៅខែកុម្ភៈ ឆ្នាំ២០១៤ ›››› ជុំទី៣ នៅខែមករា ឆ្នាំ២០១៩

## ដំណើរការត្រួតពិនិត្យ

ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់គឺធ្វើឡើងដោយក្រុមការងារ យូភីអ ដែលមានសមាសភាពមកពីរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ និងដឹកនាំដោយប្រធាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ការត្រួតពិនិត្យធ្វើឡើងផ្អែកលើព័ត៌មានដែលមានលើកឡើងតាមរយៈឯកសារសំខាន់ៗចំនួនបី ៖

**១**

រដ្ឋដែលត្រូវស្ថិតក្រោមការត្រួតពិនិត្យ ពន្យល់អំពីសមិទ្ធផល និងបញ្ហាដែលប្រឈមក្នុងការអនុវត្តអនុសាសន៍ចាប់តាំងពីការត្រួតពិនិត្យលើកមុនក្នុងរបាយការណ៍ជាតិរបស់ខ្លួន។

រដ្ឋត្រូវបានលើកទឹកចិត្តអោយធ្វើការពិគ្រោះយោបល់ជាមួយស្ថាប័នជាតិនានា និងជាមួយអង្គការសង្គមស៊ីវិល នៅពេលចងក្រងរបាយការណ៍របស់ខ្លួន។

**២**

កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលរៀបចំដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សមានព័ត៌មានដែលទទួលបានពីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ អ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងគណៈកម្មាធិការទទួលបន្ទុកតាមដានការអនុវត្តអនុសញ្ញា អំពីការវិវឌ្ឍស្ថានភាពសិទ្ធិមនុស្សនៃរដ្ឋដែលត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ។

**៣**

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សង្ខេបនូវរបាយការណ៍របស់អង្គការសង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សជាតិដាក់បញ្ចូលគ្នាឲ្យទៅជារបាយការណ៍សង្ខេបនៃភាគីពាក់ព័ន្ធ។

របាយការណ៍ពីអង្គការសង្គមស៊ីវិលផ្តោតសំខាន់ទៅលើបញ្ហាតាមវិស័យជាក់លាក់។ អង្គការនានាអាចនឹងមានបំណងធ្វើកិច្ចសហការជាមួយអង្គការដទៃទៀតផងដែរដើម្បីបង្កើតរបាយការណ៍រួមដែលបង្ហាញនូវសំឡេងរួមគ្នារបស់អង្គការសង្គមស៊ីវិលនៅលើឆាកអន្តរជាតិ។

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យ រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យក៏នឹងបង្ហាញនូវរបាយការណ៍ជាតិរបស់ខ្លួនផងដែរដោយពន្យល់និងលើកឡើងអំពីស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្ននិងវិធានការនានាក្នុងការអនុវត្តអនុសាសន៍ដែលបានទទួលក្នុងរបាយការណ៍ពីមុន។

រដ្ឋជាសមាជិកអង្គការសហប្រជាជាតិដទៃទៀត ផ្តល់អនុសាសន៍ដល់រដ្ឋដែលត្រូវត្រួតពិនិត្យអំពីវិធីអនុវត្តយ៉ាងណាឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរ។

នៅពេលដែលដំណើរការត្រួតពិនិត្យបានបញ្ចប់ រដ្ឋពាក់ព័ន្ធអាច ៖

គាំទ្រអនុសាសន៍ដែលទទួលបាន ដែលនោះគឺ ធ្វើការប្តេជ្ញាចិត្តខាងនយោបាយក្នុងការអនុវត្តអនុសាសន៍នោះនៅមុនការត្រួតពិនិត្យបន្ទាប់ ឬក៏ធ្វើការកត់សម្គាល់ទុកលើអនុសាសន៍ដែលទទួលបានទាំងនោះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org
CC BY NC SA